# របាយការណ៍ប្រចាំត្រីមាសទី ១ ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ

I. **ស្ថានភាពការងាររបស់មន្ទីរ ÷**

1. **ការិយាល័យ រដ្ឋបាល និងកិច្ចការទូទៅ ÷**

❖ **ស្ថានភាពបុគ្គលិកមន្ត្រីរាជការក្នុងមន្ទីរ**

ការងារគ្រប់គ្រងនិងដឹកនាំមន្ទីរមានថ្នាក់ដឹកនាំចំនួន ៣ រូប (ប្រធានមន្ទីរ និងអនុប្រធានមន្ទីរ ០២ រូប) និងមានការិយាល័យជំនាញចំនួន ១០ ការិយាល័យ ÷

១- ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ
២- ការិយាល័យផែនការ- ស្ថិតិ
៣- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ
៤- ការិយាល័យបណ្តុះបណ្តាល និងស្រាវជ្រាវ
៥- ការិយាល័យអភិវឌ្ឍន៍សហគមន៍
៦- ការិយាល័យផ្គត់ផ្គង់ទឹកជនបទ
៧- ការិយាល័យថែទាំសុខភាពជនបទ
៨- ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ
៩- ការិយាល័យផ្លូវជនបទ
១០- ការិយាល័យអភិវឌ្ឍន៍ជនជាតិដើមភាគតិច និងមានការិយាល័យអភិវឌ្ឍន៍ជនបទស្រុកចំនួន ០៧ និងក្រុងចំនួន ០១។

1.1. **ចំនួនមន្ត្រីរាជការ**

- សរុប ÷ ២២នាក់
- ប្រុស ÷ ១៨នាក់
- ស្រី ÷ ០៤នាក់
- ចំនួនប្រពន្ធមន្ត្រីរាជការ ÷ ១២នាក់
- ចំនួនកូន ÷ ២២នាក់
- អវត្តមាន ÷ គ្មាន
- ចំនួនមន្ត្រីរាជការដែលស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ÷ ០១នាក់
- ចំនួនមន្ត្រីរាជការផ្ទេរចូល ÷ ០១នាក់
- ចំនួនមន្ត្រីរាជការផ្ទេរចេញ ÷ គ្មាន

- ចំនួនមន្ត្រីរាជការក្របខ័ណ្ឌថ្មី ÷ គ្មាន
- ចំនួនមន្ត្រីរាជការបានតំឡើងប្រាក់បំណាច់មុខងារ ÷ គ្មាន
- ចំនួនមន្ត្រីរាជការបានតំឡើងឋានៈ ÷ គ្មាន
- ចំនួនមន្ត្រីរាជការចូលនិវត្តន៍ ÷ គ្មាន
- ចំនួនបុគ្គលិកជាប់កិច្ចសន្យា និងបុគ្គលិកបណ្តែត ÷ គ្មាន
- ចំនួនមន្ត្រីរាជការដែលទៅបំពេញបេសកកម្មនៅបរទេស ÷ គ្មាន
- ចំនួនមន្ត្រីរាជការសហការ ជាមួយកម្មវិធី និងជាដៃគូអង្គការនានា ÷ ០៦នាក់

| ល.រ | នាម និងគោត្តនាម | ភេទ | មុខងារ | សហការជាមួយអង្គការ ឬកម្មវិធី |
|---|---|---|---|---|
| ១ | សេង សារី | ប | ប្រធានមន្ទីរ | -គម្រោងឧបត្ថម្ភស្បៀងបន្ថែម- ហិរញ្ញប្បទានបន្ថែម (ADB)<br>- កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ២ | ម៉ប់ ធីរិត | ប | អនុប្រធានមន្ទីរ | កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ៣ | ឈុន ប៊ុនថេង | ប | ប្រធានការិយាល័យ | គម្រោងឧបត្ថម្ភស្បៀងបន្ថែម- ហិរញ្ញប្បទានបន្ថែម(ADB) |
| ៤ | ញាណ គង់ | ប | មន្ត្រី | - គម្រោងឧបត្ថម្ភស្បៀងបន្ថែម- ហិរញ្ញប្បទាន បន្ថែម (ADB)<br>- កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ៥ | ឃិត សុធារ៉ា | ប | មន្ត្រី | គម្រោងឧបត្ថម្ភស្បៀងបន្ថែម- ហិរញ្ញប្បទានបន្ថែម(ADB) |
| ៦ | ឆាយ សុវណ្ណា | ស | មន្ត្រី | កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |

1.2. **ការងារលិខិតចេញ-ចូល**

បានធ្វើចរាចរលិខិតស្នាម ក្នុងនោះមាន÷

- មន្ទីរបានចេញលិខិតបេសកកម្មចំនួន ÷៤៦ច្បាប់
- មន្ទីរបានចេញលិខិតទៅស្ថាប័ននានា និងក្នុងមន្ទីរចំនួន ÷១៦៩ច្បាប់
- បានទទួលលិខិតចូលពីគ្រប់ស្ថាប័ននានាចំនួន ÷៦៣ច្បាប់
- លិខិតផ្សេងៗចំនួន ÷០៧ច្បាប់

1.3. **ការងាររដ្ឋបាល និងបុគ្គលិក**

- បានរៀបលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកផ្សេងៗជូនមន្ត្រីរាជការចេញដោយមន្ទីរចំនួន ÷ ១ ច្បាប់
- បានចូលរួមប្រជុំក្រៅខេត្តចំនួន ÷០៨លើក

- បានចូលរួមប្រជុំក្នុងខេត្តចំនួន ÷២៩លើក
- បានចូលរួមប្រជុំផ្ទៃក្នុងមន្ទីរចំនួន ÷០២លើក

1.4. **ការងារបៀវត្ស និងពលកម្ម**

- ធ្វើតារាងប្រែប្រួលមន្ត្រីរាជការទៅមន្ទីរមុខងារសាធារណៈ
- កំពុងរៀបចំបៀវត្សជូនមន្ត្រីរាជការថ្នាក់មន្ទីរប្រចាំខែ
- ធ្វើរបាយការណ៍បៀវត្សមន្ត្រីរាជការទៅធនាគារអេស៊ីលីដា ភីអិលស៊ី ACLEDA PLC។

2. **ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ**

+ **ប្រភពថវិការដ្ឋផ្តល់**

- **ថវិកាអនុម័តឆ្នាំ២០១៥ = ៤៤០.៥០០.០០០៛០០**
  - ប្រាក់ជំពូក ៦០ = ៧០.០០០.០០០៛០០
  - ប្រាក់ជំពូក ៦១ = ១៧១.៥០០.០០០៛០០
  - ប្រាក់ជំពូក ៦៤ = ១៩៨.០០០.០០០៛០០
  - ប្រាក់ជំពូក ៦៣ = ១.០០០.០០០៛០០
- **ថវិកាចំណាយសម្រាប់ត្រីមាសទី១ ឆ្នាំ២០១៥ =៤៥,២៦៤,៩៦០៛០០**
  - ប្រាក់ជំពូក ៦១ = ០០៛០០
  - ប្រាក់ជំពូក ៦៤ = ៤៥,២៦៤,៩៦០៛០០
  - ប្រាក់ជំពូក ៦៣ = ០០៛០០

- ធ្វើរបាយការណ៍ចំណាយថវិកាប្រចាំខែធ្នូ ឆ្នាំ ២០១៤
- ធ្វើការបិទបញ្ជីចំណូលចំណាយថវិកាឆ្នាំ ២០១៤
- របាយការណ៍សម្រេចទូទាត់ខែធ្នូ ឆ្នាំ ២០១៤
- បានធ្វើចំណាយប្រាក់បៀវត្សខែ មករា និងខែ កុម្ភៈ ឆ្នាំ ២០១៥
- ចូលរួមសិក្ខាសាលាស្តីពីការចំណាយថវិកាកម្មវិធីនៅខេត្តសៀមរាប
- ចូលរួមបូកសរុបការងារឆ្នាំ ២០១៤ និងទិសដៅឆ្នាំ ២០១៥ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- ធ្វើរបាយការណ៍សម្រេចទូរទាត់ចំណូល-ចំណាយថវិកាឆ្នាំ ២០១៤
- ធ្វើការតែងតាំងរជ្ជទេយ្យបុរេប្រទាន និងភ្នាក់ងារបើកផ្តល់របស់មន្ទីរ
- ធ្វើការបង្កើតជើងលេខសម្រាប់ការចំណាយថវិកាឆ្នាំ ២០១៥ ទូទាត់រជ្ជទេយ្យបុរេប្រទាន និង ទូទាត់ត្រង់ឲ្យក្រុមហ៊ុន
- បើកប្រាក់បៀវត្សខែកុម្ភៈ ឆ្នាំ ២០១៥ ជូនមន្ត្រីរាជការមន្ទីរ
- រត់ការប្រាក់បៀវត្សខែមីនា ឆ្នាំ ២០១៥ ទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត

- រត់ការប្រាក់ឧបត្ថម្ភៈជូនមន្ត្រីចូលនិវត្តជន ទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត។

3. **ការងារផែនការ និងស្ថិតិ ÷**

- បានចងក្រងសៀវភៅផែនការជូននាយកដ្ឋានផែនការ និងស្ថិតិ
- ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ២០១៥ ចូលរួមប្រជុំសន្និបាតបូកសរុបការងារឆ្នាំ ២០១៤ និងទិសដៅឆ្នាំ ២០១៥ នៅសាលសន្និសិទចតុមុខ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- រៀបចំកសាងផែនការអភិវឌ្ឍន៍០៥ឆ្នាំ (២០១៥-២០១៩) របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ។

4. **ការងារអធិការកិច្ច និង សវនកម្ម÷**

- ថ្ងៃទី ១៦ មករា ២០១៥ ការចុះត្រួតពិនិត្យសវនកម្មពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង របស់ក្រសួងអភិវឌ្ឍន៍ជនបទ លើការកែតម្រូវនីតិវិធីហិរញ្ញវត្ថុ
- ថ្ងៃទី ២៧ មករា ២០១៥ ការចុះត្រួតពិនិត្យធ្វើអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល-ហិរញ្ញវត្ថុ និងការគ្រប់គ្រង ទ្រព្យសម្បត្តិរដ្ឋ ក្នុងកាលបរិច្ឆេទ២០១៤ និងបណ្តារឆ្នាំពាក់ព័ន្ធ របស់ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច។

5. **ការងារទំនាក់ទំនងសាធារណៈ**:

- ថ្ងៃទី ១៩ កុម្ភៈ ២០១៥ ចូលរួមក្នុងពិធីដាក់សម្ពោធដាក់អោយប្រើប្រាស់ជាផ្លូវការកំពង់ដរខ្នាតតូច នៅភូមិកំពង់សង្កែឃុំកំពង់ស្រឡៅមួយ ស្រុកឆែប ខេត្តព្រះវិហារ។
- ថ្ងៃទី ២៧ កុម្ភៈ ២០១៥ ចូលរួមអបអរសាទរទិវាជាតិទីក្រុងស្អាតលើកទី ០៣ ឆ្នាំ ២០១៥ ក្រោមប្រធានបទជោគជ័យទីក្រុងស្អាត ជោគជ័យទេសចរណ៍ នៅខេត្តព្រះវិហារ

II. **សកម្មភាពការងារតាមវិស័យ ÷**

1. **សកម្មភាពផ្លូវជនបទ**

- ការងាររៀបចំបញ្ជីសារពើភ័ណ្ឌ និងមូលដ្ឋានទិន្នន័យផ្លូវជនបទថ្នាក់កណ្តាល ចុះត្រួតពិនិត្យ និងតាមដាន ការចុះអនុវត្តការងារស្រង់ទិន្នន័យផ្លូវជនបទនៅខេត្តព្រះវិហារ
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយនិងបូកសរុបលទ្ធផលការងាររៀបចំបញ្ជីសារពើភ័ណ្ឌ និងមូលដ្ឋានទិន្នន័យផ្លូវជនបទព្រះរាជាណាចក្រកម្ពុជា នៅក្រសួងអភិវឌ្ឍន៍ជនបទ
    + រៀបចំយុទ្ធសាស្ត្រអនុវត្តផែនការប្រចាំឆ្នាំ២០១៥
    + បន្តជំរុញលទ្ធផលការងារតាមពេលវេលាដែលបានគ្រោងទុក
    + ពិនិត្យតាមដាន និងជំរុញលទ្ធផលការងារអនុវត្តតាមផែនការការងារក្រោមការទទួលខុសត្រូវ របស់ប្រធានក្រុមការងារទទួលបន្ទុកតាមគោលដៅ
    + ផ្សព្វផ្សាយលទ្ធផលការងាររបស់ក្រុមនិមួយៗ

+ កម្មវិធីកសាងផែនទី

- ក្រុមការងាររៀបចំបញ្ជីសារពើភ័ណ្ឌនិងមូលដ្ឋានទិន្នន័យផ្លូវជនបទថ្នាក់ខេត្តបានចុះស្រង់ទិន្នន័យផ្លូវលំជនបទទទួលបានលទ្ធផលដូចខាងក្រោម ÷

- ផ្លូវប្រភេទលេខ០១ ចំនួន ០៤ខ្សែ ប្រវែង ៩៥,៥ គីឡូម៉ែត្រ
- ផ្លូវប្រភេទលេខ០២ ចំនួន ១៤ខ្សែ ប្រវែង ២៦៩,៥ គីឡូម៉ែត្រ
- ផ្លូវប្រភេទលេខ០៣ ចំនួន ៣៦ខ្សែ ប្រវែង ៣៩៣,៣ គីឡូម៉ែត្រ
- ផ្លូវប្រភេទលេខ០៤ ចំនួន ៣២៤ខ្សែ ប្រវែង ៤៩៥ ០៦៩ គីឡូម៉ែត្រ

ទិន្នន័យផ្លូវជនបទទាំងបួនប្រភេទសរុបចំនួន ៣៧៨ ខ្សែ ស្មើ ១ ២៥៣,៣៦៩ គម។

- សកម្មភាពការងារចុះស្រង់ទិន្នន័យ

- ផ្លូវប្រភេទលេខ ០៣ ចំនួន ០២ខ្សែប្រវែង ៣១ ៧០០ ម៉ែត្រ
- ផ្លូវប្រភេទលេខ ០៤ ចំនួន ០៦ខ្សែប្រវែង ២១ ៤៩៤ ម៉ែត្រ

- ការងារធ្វើបច្ចុប្បន្នភាព

- ផ្លូវប្រភេទលេខ ០២ ចំនួន ០១ខ្សែប្រវែង ១១.៦០០ម៉ែត្រ និងលូគ្រប់ប្រភេទចំនួន ១៥កន្លែង
- ថ្ងៃទី ០៤ ខែមករា ឆ្នាំ២០១៥ ប្រជុំក្រុមការងាររៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវនិងមូលដ្ឋានទិន្នន័យផ្លូវជនបទដើម្បីរៀបចំផែនការសកម្មភាពការងារចុះស្រង់ទិន្នន័យ និងធ្វើបច្ចុប្បន្នភាពផ្លូវជនបទនៅក្នុងខេត្ត
- ថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០១៥ ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ និងបូកសរុបលទ្ធផលការងារស្តីពីការរៀបចំបញ្ជី សារពើភ័ណ្ឌផ្លូវ និងមូលដ្ឋានទិន្នន័យផ្លូវជនបទ នៃព្រះរាជាណាចក្រកម្ពុជាប្រចាំឆ្នាំ ២០១៤ នៅសណ្ឋាគារភ្នំពេញរាជធានីភ្នំពេញ
- ថ្ងៃទី ២៤-២៦ ខែកុម្ភៈ ឆ្នាំ២០១៥ ចុះស្រង់ទិន្នន័យផ្លូវជនបទ និងធ្វើបញ្ជីសារពើភ័ណ្ឌផ្លូវនៅស្រុកជាំក្សាន្ត បានប្រវែងផ្លូវសរុប ៤៩.២៥គ.ម។

2. **ការងារផ្គត់ផ្គង់ទឹកជនបទ**

- បានរៀបចំគម្រោងសំណើសម្រាប់ផែនការអនុវត្តឆ្នាំ២០១៥ ទៅនាយកដ្ឋានជំនាញ
- នៅថ្ងៃទី ២៦-២៧ ខែកុម្ភៈ ឆ្នាំ ២០១៥ បានចូលរួមសម្របសម្រួលវគ្គបណ្តុះបណ្តាលដល់យុវជន ស្តីពីទីផ្សារបង្កន់អនាម័យនៅសាលប្រជុំកាកបាតក្រហមខេត្តព្រះវិហារ ដែលមានអ្នកចូលរួមសរុប ៥២នាក់ ស្ត្រី ១១នាក់ ដោយមានការគាំទ្រពីអង្គការទស្សនៈពិភពលោកប្រចាំខេត្តព្រះវិហារ
- នៅថ្ងៃទី ០៦-០៧ ខែ មិនា ឆ្នាំ ២០១៥ បានសម្របសម្រួលវគ្គបណ្តុះបណ្តាលដល់នាយកសាលា លោកគ្រូ អ្នកគ្រូស្តីពីភាពជាម្ចាស់ការនៃការលើកកម្ពស់អនាម័យសុខភាពនៅថ្នាក់សាលារៀន នៅសាលាប្រជុំកាកបាត ក្រហមខេត្តព្រះវិហារ ដែលមានអ្នកចូលរួមសរុប

៦៤នាក់ ស្ត្រី ២៨នាក់ ដោយមានការគាំទ្រពីអង្គការ ទស្សនៈពិភពលោកប្រចាំខេត្តព្រះវិហារ។

3. **ការងារថែទាំសុខភាពជនបទ**
   - ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥ ចូលរួមដំណើរទស្សនៈកិច្ចសិក្សាដកបទពិសោធន៍ត្រួតពិនិត្យស្តីពីប្រព័ន្ធចែកចាយទឹកស្អាតជនបទតាមទុយោនៅខេត្តបន្ទាយមានជ័យ។
4. **ការងារបណ្តុះបណ្តាល និង ស្រាវជ្រាវ ៖**
   - ចូលរួមសិក្ខាសាលាផ្សព្វផ្សាយសារាចរណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធីនៅខេត្តសៀមរាប
   - ថ្ងៃទី ១១ កុម្ភៈ ឆ្នាំ ២០១៥ ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ និងបូកសរុបការងាររៀបចំបញ្ជីសារពើភ័ណ្ឌ និងមូលដ្ឋានទិន្នន័យផ្លូវជនបទនៃព្រះរាជាណាចក្រកម្ពុជាប្រចាំឆ្នាំ២០១៤
   - ចូលរួមពិធីផ្សព្វផ្សាយលទ្ធផលសន្និបាតត្រួតពិនិត្យការងារឆ្នាំ ២០១៤ និងទិសដៅឆ្នាំ ២០១៥ របស់ក្រសួងមហាផ្ទៃ
   - ថ្ងៃទី ២៥ កុម្ភៈ ឆ្នាំ ២០១៥ ចូលរួមបូកសរុបការងារយោធាឆ្នាំ ២០១៤ និងទិសដៅឆ្នាំ ២០១៥ នៅទីបញ្ជាការឯកភាពខេត្តព្រះវិហារ
   - ថ្ងៃទី ០៣-០៤ មីនា ឆ្នាំ ២០១៥ ចូលរួមសន្និសិទ្ធជាតិអាហារូបត្ថម្ភនៅរាជធានីភ្នំពេញ។
5. **ការងារអភិវឌ្ឍន៍សហគមន៍៖**
   - បានរៀបចំគម្រោងសំណើស្តីពីគម្រោងអភិវឌ្ឍន៍ភូមិចំរុះ និងគម្រោងសន្តិសុខស្បៀងសម្រាប់ផែនការអនុវត្ត ឆ្នាំ២០១៥ ទៅនាយកដ្ឋាន។
6. **ការងារសេដ្ឋកិច្ចជនបទ៖ គ្មាន**
7. **ការងារជនជាតិដើមភាគតិច៖**
   - ថ្ងៃទី ១៣-១៤ ខែមករា ឆ្នាំ ២០១៥ បានចូលរួមសម្របសម្រួលការពិនិត្យពិភាក្សា និងឯកសារលើការពង្រាង បទបញ្ជាផ្ទៃក្នុងសហគមន៍ក្នុងការប្រើប្រាស់ដីជាកម្មសិទ្ធសម្ហូហភាពកំណត់តំបន់ដី ដែលប្រើប្រាស់ក្នុងដំណើរការចុះបញ្ជីដីជាកម្មសិទ្ធសម្ហូហភាពក្នុងភូមិប្រមេរភូមិបុះធំភូមិស្រែព្រាង ឃុំប្រមេរ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ ដែលមានសមាសភាពចូលរួមសរុប៣៣ នាក់ ស្រី២១នាក់
   - បានចូលរួមប្រជុំពេញអង្គក្នុងការអនុម័តលក្ខន្តិកៈសហគមន៍ជនជាតិដើមភាគតិចកួយ នៅភូមិក្រាំងដូង អន្លង់ស្វាយ ប្រមេរ ស្រែព្រាង និងភូមិបុស្សធំ ស្រុកត្បែងមានជ័យ
   - បានចូលរួមប្រជុំពេញអង្គកំណត់បទបញ្ជាផ្ទៃក្នុងនៅភូមិបុស្សធំ ភូមិប្រមេរ ភូមិស្រែព្រាង ឃុំប្រមេរ ស្រុកត្បែងមានជ័យ។
8. **ការងារយេនឌ័រ ៖**

- ថ្ងៃទី ០៥ មីនា ២០១៥ ចូលរួមជាអធិបតីភាពក្នុងពិធីសំណេះសំណាល ដើម្បីអបអរសាទរខួបលើកទី ១០៤ ទិវាអន្តរជាតិ ៨ មីនា ២០១៥ នៅសាលាស្រុកត្បែងមានជ័យ
- ចុះសួរសុខទុក្ខ និងជូនអំណោយក្នុងឱកាសទិវាសិទ្ធិនារី ០៨ មីនា ២០១៥ ដល់មន្ត្រីជានារីចំនួន ០៥រូប ដែលជាអំណោយដ៏ថ្លៃថ្លារបស់ ឯកឧត្តម ជា សុផារ៉ា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងម្នាក់ៗទទួល បានថវិកាចំនួន ១៥០,០០០៛ (មួយរយហាសិបពាន់រៀលគត់) និងសារ៉ុង ០១។

9. **ការងារ** NGOs÷
   - នៅថ្ងៃទី ២៤-២៥ ខែមករា ឆ្នាំ ២០១៥ បានចូលរួមសម្របសម្រួលដល់អាជ្ញាធរឃុំ ភូមិ និងជនបង្គោលអនាម័យភូមិ កិច្ចប្រជុំស្តីពី ការពិនិត្យឡើងវិញ និងការរៀបចំផែនការ ឆ្នាំ ២០១៤-២០១៥ សម្រាប់ការអនុវត្តន៍កម្មវិធីសហគមន៍ដឹកនាំអនុវត្តអនាម័យទាំងស្រុង (CLTS) ដែលមានអ្នកចូលរួមសរុប ៣៦នាក់ ស្ត្រី ១១នាក់ ដោយមានការគាំទ្រពីអង្គការទស្សនៈពិភពលោកប្រចាំស្រុករវៀង
   - នៅថ្ងៃទី ២៨-២៩ ខែ មករាឆ្នាំ ២០១៥ បានសម្របសម្រួលប្រជុំស្តីពី ការចុះប៉ាន់ប្រមាណពីតម្រូវ ការអណ្តូង និងការចុះកំណត់ទីតាំងអណ្តូងទឹក នៅក្នុងភូមិសំបូរ ភូមិជោគជ័យ និងភូមិកាឡូតក្នុងភូមិគោលដៅរបស់អង្គការទស្សនៈពិភពលោកប្រចាំស្រុកឆែប ដែលមានអ្នកចូលរួមសរុប ១២៣នាក់ ស្ត្រី ៩០នាក់ និងចុះកំណត់ទីតាំងអណ្តូងបានចំនួន ៧អណ្តូងក្នុងឃុំភូមិនេះ។

10. **គម្រោង / កម្មវិធី** ÷

   10.1. **គម្រោងខ្នាតតូចស្បៀងបន្ថែម-ហិរញ្ញវត្ថុបន្ថែម** (ADB)
   - ថ្ងៃទី ០៩ ខែមករា ឆ្នាំ ២០១៥ លោកប្រធានកម្មវិធីថ្នាក់ខេត្ត បានចូលរួមអមដំណើរគណៈប្រតិភូរបស់អង្គការយូនីសេហ្វផ្នែកកម្មវិធីទឹកស្អាត និងអនាម័យ ដឹកនាំដោយលោកស្រី Belinda Abraham ប្រធានកម្មវិធីបានចុះមកទស្សនកិច្ចពិនិត្យការងារអនុវត្តសកម្មភាពស្តីពីទឹកស្អាត និងអនាម័យជនបទរបស់ថ្នាក់ខេត្ត ស្ថិតនៅឃុំថ្មី ស្រុកគូលែន
   - ថ្ងៃទី ១៣-១៤ ខែមករា ឆ្នាំ ២០១៥ លោកប្រធានកម្មវិធី និងមន្ត្រីទទួលបន្ទុកផ្នែកសុខភាពនៃកម្មវិធីទឹកស្អាត និងអនាម័យជនបទ បានចូលរួមកិច្ចប្រជុំស្តីពីការត្រួតពិនិត្យឡើងវិញការអនុវត្តកម្មវិធីឆ្នាំ ២០១៤ និងទិសដៅឆ្នាំ ២០១៥ របស់កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ នៅខេត្តបាត់ដំបង ដោយមានអ្នកចូលរួមមកពីខេត្តគោលដៅចំនួន ១៥ខេត្ត

- ថ្ងៃទី ០៤-០៦ ខែកុម្ភៈ ឆ្នាំ ២០១៤ ចុះត្រួតពិនិត្យក្រាលក្រួសក្រហម០១ខ្សែ ប្រវែង ៨,៣២២ ម៉ែត្រ និងសំណង់ សិល្បៈការចំនួន ១០កន្លែង លទ្ធផលសម្រេចបាន អ្នកទទួលការលើកតួផ្លូវ បានប្រវែង ៨,០០០ម និងលូចំនួន ១១ កន្លែង
- ថ្ងៃទី ០២-០៣ ខែមីនា ឆ្នាំ២០១៥ ចុះត្រួតពិនិត្យផ្លូវក្រាលក្រួសក្រហម០១ខ្សែ និងសំណង់ សិល្បការ ចំនួន១២កន្លែង នៅភូមិពោធិ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ លទ្ធផលអ្នក ទទួលការអនុវត្តលើកតួផ្លូវ ដីស បានប្រវែង ៨ ៣២២ម និងសំណង់សិល្បៈបានចំនួន ១០កន្លែង
- ថ្ងៃទី ០៩-១០ ខែមីនា ឆ្នាំ២០១៥ ចុះត្រួតពិនិត្យការសាងសង់ដាឡូ ប្រវែង៩ម x ៥ម x៣ម (ចំណុចអូរ សោម) លើខ្សែផ្លូវក្រាលក្រួសក្រហម០១ខ្សែប្រវែង៨.៣២២ម នៅឃុំពោធិ ស្រុក ត្បែងមានជ័យ លទ្ធផល អ្នកទទួលការ ទើបតែចាក់បានគ្រឹះបាតខាងក្រោមកម្ពស់ ០,៥ម តែ ប៉ុណ្ណោះ។

**10.2. កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ នៅតាមសាលារៀន និងសហគមន៍ (គាំទ្រថវិកាដោយ UNICEF)**

- ថ្ងៃទី ០៩ ខែមករា ឆ្នាំ ២០១៥ លោកប្រធានកម្មវិធីថ្នាក់ខេត្ត បានចូលរួមអមដំណើរ គណៈប្រតិភូរបស់អង្គការ យូនីសេហ្វផ្នែកកម្មវិធីទឹកស្អាត និងអនាម័យដឹកនាំដោយលោកស្រី Belinda Abraham ប្រធានកម្មវិធីបានចុះ មកទស្សនកិច្ចពិនិត្យការងារអនុវត្តសកម្មភាពស្តីពី ទឹកស្អាត និងអនាម័យជនបទរបស់ថ្នាក់ខេត្ត ស្ថិតនៅឃុំថ្មី ស្រុកគូលែន។
- ថ្ងៃទី ១៣-១៤ ខែមករា ឆ្នាំ ២០១៥ លោកប្រធានកម្មវិធី និងមន្ត្រីទទួលបន្ទុកផ្នែកសុខភាព នៃកម្មវិធីទឹកស្អាត និងអនាម័យជនបទ បានចូលរួមកិច្ចប្រជុំស្តីពីការត្រួតពិនិត្យឡើងវិញការ អនុវត្តកម្មវិធីឆ្នាំ២០១៤ និងទិស ដៅឆ្នាំ២០១៥ របស់កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ជនបទនៅខេត្តបាត់ដំបងដោយមានអ្នកចូលរួមមក ពីខេត្តគោលដៅចំនួន ១៥ខេត្ត៕